រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

# អនុក្រឹត្យលេខ ២៣ អនក្រ
# ស្តីពីការប្តូរឈ្មោះទីរួមខេត្ត សង្កាត់ ក្នុងខេត្តកំពង់ស្ពឺ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្តកំពង់ស្ពឺ មកជាស្រុកច្បារមន ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិត្រស់ ឃុំសេរីភាព ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួនប្រាំ ចំណុះទីរួមខេត្ត មកជាឃុំចំនួនប្រាំ ចំណុះស្រុកច្បារមនគឺ៖

- សង្កាត់ ច្បារមន មកជា ឃុំ ច្បារមន
- សង្កាត់ ឯករាជ មកជា ឃុំ កណ្តាលដុំ
- សង្កាត់ សន្តិភាព មកជា ឃុំ រការធំ
- សង្កាត់ សេរីភាព មកជា ឃុំ ស្វាយក្រវ៉ាន់
- សង្កាត់ សុព័រទេព មកជា ឃុំ សុព័រទេព

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥ :** អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ២៤ អនក្រ
# ស្តីពីការប្តូរឈ្មោះ ស្រុកធីរូមខេត្ត
# និង សង្កាត់ក្នុងខេត្ត សៀមរាប

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះស្រុក សៀមរាប មកជា ស្រុក ប្រាសាទបាគង ។

**មាត្រា ២ :** ត្រូវបានប្តូរទីរួមខេត្ត របស់ខេត្តសៀមរាប មកជា ស្រុក សៀមរាប ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិ បន្ទាយចាស់ ឃុំ ស្លក្រាម ។

**មាត្រា ៣ :** ត្រូវបានប្តូរឈ្មោះសង្កាត់ ចំនួន ១០ ចំណុះទីរួមខេត្ត មកជា ឃុំ ចំនួន ១០ ចំណុះស្រុក សៀមរាប គឺ ÷

-សង្កាត់ ១ មកជា ឃុំ ស្លក្រាម

-សង្កាត់ ២ មកជា ឃុំ ស្វាយដង្គុំ

-សង្កាត់ ៣ មកជា ឃុំ គោកចក

-សង្កាត់ ៤ មកជា ឃុំ សាលាកំរើក

www.pheakdeylaw.com